# ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក





## រៀបចំសម្រាប់

## វេទិកាថ្នាក់ជាតិលើកទី ៥
## ស្តីពី ការជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍
## កសិ-ពាណិជ្ជកម្មកម្ពុជា
## សៀមរាប, ថ្ងៃទី ០១ ខែធ្នូ ២០១៧


**ដោយ លោក ប្រាក់ សេរីវឌ្ឍន៍ ប្រធានអង្គការ CIRD**

Tel: 012 88 79 66 – E-mail: praksereyvath@cird.org.kh

# ១. ស្ថានភាពទូទៅនៃវិស័យបន្លែនៅកម្ពុជា

- កសិកម្មចូលរួមចំណែកក្នុងផលិតផលក្នុងស្រុកដុល (GDP) ប្រមាណ 26,3% នឹង មានប្រជាជនប្រមាណ70%នៃកំល្លាំងពលកម្មសរុបក្នុងប្រទេសធ្វើការងារលើវិស័យនេះ
- **ដោយឡែកដំណាំបន្លែដើរតួនាទីសំខាន់ទី៣** បន្ទាប់ពីដំណាំស្រូវ នឹងត្រី-សាច់ក្នុងការបរិភោគព្រមទាំងបំពេញនូវអាហារូបត្ថម្ភ និងបញ្ហាកង្វះជីវជាតិ
- បន្លែជាកសិផលដែលមានសារៈសំខាន់ទាំងផ្នែកអាហារូបត្ថម្ភ និងទាំងផ្នែកសេដ្ឋកិច្ច ប៉ុន្តែបច្ចុប្បន្នបានដាំដុះលើផ្ទៃដីកសិកម្មសរុបប្រមាណតែ ១,៨% ប៉ុណ្ណោះ បើធៀបទៅនឹងដំណាំផ្សេងៗទៀតនៅកម្ពុជា។







# ១. ស្ថានភាពទូទៅនៃវិស័យបន្លែ នៅកម្ពុជា(ត)

## ការវិវត្តន៍នៃផលិតកម្មបន្លែនាពេល១០ឆ្នាំចុងក្រោយ (២០០៦-២០១៦)



# ១. ស្ថានភាពទូទៅនៃវិស័យបន្លែនៅកម្ពុជា(ត)

## ផលិតកម្ម និង តម្រូវការបន្លែ

- ផលិតកម្មបន្លែហាក់មានការកើនឡើងនាពេលថ្មីៗនេះ ៖

✓ ផ្ទៃដីដាំដុះ (៥២-៥៤ពាន់ហ.ត)

✓ បរិមាណផល (៤០០-៤២០ពាន់តោន)

✓ ទិន្នផល (៨-៨,៥តោន/ហ.ត)

- ដំណាំបន្លែមានលក្ខណៈសមស្របសម្រាប់ការដាំដុះជាលក្ខណៈគ្រួសារដែលកសិករមានទម្លាប់ដាំដុះជាយូរមកហើយ (អាកាសធាតុសមស្របសម្រាប់ការដាំដុះគឺចាប់ពីខែតុលា-មករានិងពិបាកខ្លាំងនារដូវក្តៅពីខែមិនា-មិថុនា ដែលនាំឱ្យខ្សែសង្វាក់ផ្គត់ផ្គង់មិនអាចធានាបានទៀងទាត់ពេញមួយឆ្នាំ)។





# ១. ស្ថានភាពទូទៅនៃវិស័យបន្លែនៅកម្ពុជា(ត)

## ផលិតកម្ម និង តម្រូវការបន្លែ (ត)

- តំបន់ដាំដុះបន្លែច្រើនជាងគេមាននៅខេត្ត៖ កណ្ដាល កំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង សៀមរាប និងកំពត ដែលមានផ្ទៃដីដាំដុះ ប្រមាណ ៥៧% ផ្ទៃដីដាំបន្លែសរុប
- តម្រូវការបន្លែនៅស្រុកមាននិន្នាការកើនឡើងដោយសារ៖
  - ✓ ការបរិភោគបន្លែមានការកើនឡើង៖
  - អ្នកជនបទហូបបន្លែប្រមាណ 35គ.ក/នាក់/ឆ្នាំ
  - អ្នកទីប្រជុំជនឬទីក្រុងហូបបន្លែ 45គ.ក/នាក់/ឆ្នាំ
  - ការប្រើប្រាស់នេះនៅស្ថិតក្រោមកំរិតណែនាំរបស់ FAO គឺ 73គ.ក/នាក់/ឆ្នាំ។



# ១. ស្ថានភាពទូទៅនៃវិស័យបន្លែ នៅកម្ពុជា(ត)

## ផលិតកម្ម និង តម្រូវការបន្លែ(ត)

✓ កំណើនប្រជាជននិងភ្ញៀវទេសចរ៖

- សម្រាប់មនុស្ស ១៥,៨លាននាក់ ត្រូវការប្រើប្រាស់បន្លែប្រមាណ ៩៣០ពាន់តោន
- ផលិតផលក្នុងស្រុកមានប្រមាណ ៤២០ពាន់តោន
- ដូច្នេះត្រូវមានការនាំចូលពីបរទេសប្រមាណ ៥០%





# ១. ស្ថានភាពទូទៅនៃវិស័យបន្លែនៅកម្ពុជា(ត)

- ✓ ប្រភពបន្លែនាំចូលពីខាងក្រៅ៖ វៀតណាម ថៃ និង ចិន
- ✓ ប្រភេទបន្លែនាំចូលពីខាងក្រៅមានដូចជា៖ ការ៉ុត ខ្ទឹមបារាំង ប៉េងប៉ោះ ស្ពៃក្តោប ស្ពៃបូកគោ ម្ទេសហាវ៉ៃ ខ្ទឹមស-ក្រហម និងដំឡូងបារាំង។

- – ការនាំចូលមានច្រើនចាប់ពីខែមេសា-តុលាចំពេលអាកាសធាតុនៅកម្ពុជាក្តៅខ្លាំង និងរងទឹកជំនន់ជោរជន់ខ្លាំង។
- – ចាប់ពីខែវិច្ឆិកា-មីនា ការនាំចូលមានការធ្លាក់ចុះច្រើនពិសេសប្រភេទបន្លែស្លឹក
- – ការនាំចូលសំដៅមករាជធានីភ្នំពេញពិសេសផ្សារដើមគរ និងផ្សារនាគមាសហើយត្រូវចែកចាយបន្តទៅបណ្តាខេត្តផ្សេងៗទៀត។

# ១. ស្ថានភាពទូទៅនៃវិស័យបន្លែនៅកម្ពុជា(ត)

## បញ្ហាប្រឈមសំខាន់ៗនៅក្នុងផលិតកម្មនិងទីផ្សារ៖

- អាកាសធាតុត្រូពិកក្តៅហើយសើម សមស្របចំពោះបន្លែក្នុងតំបន់ត្រូវពិកប៉ុន្តែពិបាកក្នុងការដាំដុះបន្លែតំបន់ត្រជាក់បង្គួរដែលមានតម្រូវការទីផ្សារដូចជា ការ៉ុត ដំឡូងបារាំង ។ល។)
- ខ្វះប្រភពទឹកនិងប្រព័ន្ធស្រោចស្រពនារដូវប្រាំង (តិចជាង1/3 នៃដីដាំបន្លែមានប្រភពទឹកស្រោចស្រព)
- ខ្វះដីដាំដុះបន្លែនារដូវទឹកជំនន់
- អាកាសធាតុប្រែប្រួល ភ្លៀងធ្លាក់មិនទៀងទាត់ ពេលចាប់ផ្តើមរដូវនិមួយៗមិនទៀងទាត់នាំឱ្យការរៀបចំផែនការដាំដុះជួបការលំបាកខ្លាំងតម្រូវឱ្យមានការវិនិយោគលើការដាំដុះក្នុងផ្ទះកញ្ចក់ ឬ ផ្ទះសំណាញ់ជាដើមដើម្បីធានាទិន្នផលសមស្រប។

# ១. ស្ថានភាពទូទៅនៃវិស័យបន្លែនៅកម្ពុជា(ត)

- បញ្ហាដូចរៀបរាប់ខាងដើមនាំឲ្យកសិករជាទូទៅមិនអាចផលិតនិងផ្គត់ផ្គង់បន្លែក្នុងស្រុកដល់ទីផ្សារបានទៀងទាត់និងពេញមួយឆ្នាំ នាំឲ្យកសិករពីបាកឈោងចាប់ទីផ្សារមួយជាក់លាក់ដែលធានាដោយកិច្ចសន្យា។
- សម្ភារៈផលិតកម្មភាគច្រើននាំចូលពីប្រទេសជិតខាង គួបផ្សំជាមួយនឹងកង្វះខាតបច្ចេកទេសផលិតក្នុងចំណោមកសិករធ្វើឲ្យថ្លៃដើមផលិតខ្ពស់ មិនអាចប្រកួតប្រជែងជាមួយបន្លែនាំចូល។
- ការបាត់ភាពប្រកួតប្រជែងទីផ្សារគឺជាកត្តារាំងស្ទះធំមួយក្នុងការបង្កើនផលិតកម្មបន្លែដើម្បីកាត់បន្ថយឬជំនួសបន្លែនាំចូល។

# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក

ក្នុងការគាំទ្រលើវិស័យបន្លែ CIRD ផ្តោតសំខាន់លើផលិតកម្ម ក្រុមឬអង្គការផលិតករ និង ការបង្កើនសមត្ថភាពផលិតករក្នុងការឈោងចាប់ទីផ្សារ។ ជាទូទៅការគាំទ្រ លើវិស័យបន្លែគឺជាផ្នែកឬសមាសភាគមួយនៃគម្រោងអភិវឌ្ឍកសិកម្មនិរន្តរភាពនៅតាមតំបន់គោលដៅជាក់លាក់មួយចំនួនដែលគម្រោងទាំងនោះទទួលមូនិធិពីដៃគូរអភិវឌ្ឍន៍ដូចជា EU ប្រទេសបារាំង ប៊ែលហ្ស៊ិក អេស្ប៉ាញ... ហើយដែលCIRD អនុវត្តរួមគ្នាក្នុងភាពជាដៃគូរជាមួយអង្គការអន្តរជាតិមួយចំនួនដូចជា

ADG, Cives Mundi, GRET, …





# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក (ត)

## ជំហានជាយុទ្ធសាស្ត្រក្នុងការគាំទ្ររបស់គម្រោង៖

1) ការសិក្សាទីផ្សារបន្លែនៅតាមតំបន់អន្តរាគមន៍របស់គម្រោង ៖ តម្រូវការ ការផ្គត់ផ្គង់ ភាពងាយស្រួល បញ្ហាដែលជួបប្រទះ ការប្រឈម សក្តានុពលតួអង្គសំខាន់ៗ និង អ្នកពាក់ពន្ធ័

2) ការសិក្សាអំពីផលិតកម្ម៖ ស្ថានភាពបច្ចុប្បន្ន បញ្ហាដែលជួបប្រទះ ការប្រឈម និង សក្តានុពលក្នុងការបង្កើនផលិតភាព និង គុណភាព

3) ការកំណត់អំពីអាទិភាព និង ការរៀបចំផែនការសកម្មភាព និង យុទ្ធសាស្ត្ររបស់គម្រោងក្នុងគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារដើម្បីឲ្យការផ្គត់ផ្គង់បន្លែដោយផលិតករអាចឆ្លើយតបបានប្រសើរជាងមុនទៅនឹងតម្រូវការទីផ្សារ។

# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក (ត)

ការគាំទ្រដែល CIRD និងអង្គការដៃគូរ (ADG, GRET, Cives Mundi) បានអនុវត្តន៍កន្លងមកតាមរយៈគម្រោងអភិវឌ្ឍន៍នានាដូចជាគម្រោង AFSA, APICI, DCI-STR, ...៖

**១. ការបង្កើនផលិតភាព និង គុណភាព (ទិដ្ឋភាពបច្ចេកទេស)៖**

- ការបណ្តុះបណ្តាលកសិករនិងតាមដានលើការអនុវត្តន៍បច្ចេកទេសកែលំអដី ដាំដុះ ថែទាំ ប្រមូលផល និងគ្រប់គ្រងផលិតផលក្រោយប្រមូលផល
- ការគាំទ្រដល់កសិករឆ្នើមក្នុងការរៀបចំកសិដ្ឋានបង្ហាញ និង ចូលរួមបង្ហាត់បង្រៀនដល់កសិករដទៃទៀត
- ការផ្គត់ផ្គង់សម្ភារៈនិងឧបករណ៍ផលិតកម្មបន្លែ
- ការគាំទ្រលើការដោះស្រាយបញ្ហាទឹក (ជីកឬស្តារស្រះទឹក បំពាក់សម្ភារៈ/ប្រពន្ធ័ស្រោចស្រព បញ្ចូលនូវបច្ចេកទេសសន្សំសំចៃទឹក ...)។

# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ
# ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក (ត)











# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក (ត)







## ២. ការសម្របសម្រួលបង្កើតក្រុមផលិតករឬសហគមន៍កសិកម្មដើម្បីសម្រួលដល់ការផ្លាស់ប្តូរបទពិសោធន៍ក្នុងការផលិត និង ការរកទីផ្សារ៖

- សម្របសម្រួលកសិករផលិតបន្លែឲ្យរៀបចំចងក្រងជាក្រុមផលិតករ និង សហគមន៍កសិកម្មតាមរយៈការសិក្សាពីលទ្ធភាព ការរៀបចំគោលការណ៍ ឬលក្ខន្តិកៈ ការប្រជុំពិគ្រោះយោបល់ និងរៀបចំសន្និបាតកំណើតតំបូង

- ពង្រឹងសមត្ថភាពក្រុមផលិតករ និង សហគមន៍កសិកម្មលើការរៀបចំផែនការនិង ការគ្រប់គ្រងជំនួញក្រុម/សហគមន៍

- ការរៀបចំស្តង់ដារគុណភាព ប្រព័ន្ធត្រួតពិនិត្យ ពាណិជ្ជសញ្ញាផលិតផល និងការផ្សព្វផ្សាយផលិតផលរបស់ក្រុមឬសហគមន៍។

# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក (ត)

## ៣. ការគាំទ្រលើការធ្វើពាណិជ្ជកម្មបន្លែសហគមន៍

- ការសិក្សានិងកំណត់នូវប្រតិបត្តិករទីផ្សារសក្តានុពលក្នុងការសហការជាមួយក្រុមផលិតករ និង សហគមន៍កសិកម្ម (អ្នកប្រមូលទិញក្នុងមូលដ្ឋាន អ្នកលក់ដុំ សណ្ឋាគារ ភោជនីយដ្ឋាន, អ្នកប្រើប្រាស់ផ្ទាល់ ...)
- ការគាំទ្រដល់អ្នកប្រមូលទិញក្នុងមូលដ្ឋានក្នុងការបង្កើនសមត្ថភាពប្រមូលទិញ និង លក់ចេញនូវផលិតផលបន្លែក្នុងស្រុក៖ បង្កើនការសហការណ៍ជាមួយផលិតករក្នុងការរៀបចំផែនការផលិត ការផ្សព្វផ្សាយផលិតផល សម្ភារៈវិចខ្ចប់ ទុកដាក់ និងដឹកជញ្ជូនបន្លែដែលអាចធានាគុណភាព។






# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក (ត)

- ការភ្ជាប់ទំនាក់ទំនងរវាងក្រុមផលិតករ និង សហគមន៍កសិកម្មជាមួយនឹងប្រតិបត្តិករទីផ្សារ
- ការសម្របសម្រួលការប្រជុំ និង ការចរចាររវាងក្រុមផលិតករឬសហគមន៍កសិកម្មជាមួយនឹងប្រតិបត្តិករទីផ្សារជាកិច្ចសន្យាទិញ-លក់។
- ការផ្សព្វផ្សាយទីផ្សារដោយការបញ្ជាក់ពីគុណភាពដើម្បីញែកផលិតផលរបស់ក្រុមឬសហគមន៍កសិកម្មឲ្យដាច់ចេញពីផលិតផលនាំចូល និងផលិតផលមិនមានសុវត្ថិភាពផ្សេងទៀត
- ផ្សព្វផ្សាយព័តមានទីផ្សារដល់ផលិតករបន្លែជាដៃគូរក្នុងការរៀបចំផែនការផ្គត់ផ្គង់ និង កាផលិត។






# ២. ការគាំទ្រដល់ផលិតករ និង ប្រតិបត្តិករទីផ្សារ ក្នុងការជម្រុញទីផ្សារផលិតផលបន្លែក្នុងស្រុក (ត)

- Khmer Farmer Garden (Phnom Penh)








បន្លែស្រស់ ម្ចាស់ស្អាត




cellcard LTE
4:41 AM
28%
Thai Soda added 5 new photos.
2 hrs ·
You and 4 others
1 Share
Like
Comment
Share
Khmer Times
Sponsored ·
Line of beauty: a make-up artist's story -








ALPHABET
october 2017

# ឯកសារយោង


- ប្រាក់ សេរីវ័ឌ្ឍន៍, ១៩៩៤ – បញ្ហាដែលផលិតករដំណាំបន្លែក្នុងគ្រួសារគ្រុយស៊ីហ្វែជួបប្រទះលើទិដ្ឋភាពបច្ចេកទេស និង សេដ្ឋកិច្ច – សាកលវិទ្យាភូមិន្ទកសិកម្ម – ៩៦ ទំព័រ
- BAL P., 1994 - A study on production and commercialisation of Brassicae in Cambodia, Synthesis – URA/GRET, 49p + appendix.
- BARTEAU J. PRAK Sereyvath. et al., 1997 - Programme de spécialisation en horticulture niveau 2 - Lycée Agricole de Prek Leap/LEGTA, 101p.
- FIARD F. et TOP F., 1994 - Les exploitation maraîchères de la plaine des quatre-bras (Cambodge), Fonctionnements et problèmes rencontrés pour la production de choux, mémoire de fin d'études - ISARA, 79p+ annexes et synthèse.
- លោក ហ៊ូ ពុទ្ធា, 2017, វឌ្ឍនភាព បញ្ហាប្រឈម និង យុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំបន្លែនៅកម្ពុជា(បទបង្ហាញសម្រាប់សិក្ខាសាលាដែលរៀបចំដោយ GDA និង ICCO ខែមេសា ឆ្នាំ២០១៧, នាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ,
- Giang Duong, Khin Pisey, April 2016 – The vegetable sector in Cambodia, the primary finding presentation – FAO and Nuppun
- អង្គការ GRET និងអង្គការ CIRD, 2017 - របាយការណ៍និងបទបង្ហាញរបស់គម្រោង APICI
- អង្គការ ADG និងអង្គការ CIRD, 2012 - របាយការណ៍និងបទបង្ហាញរបស់គម្រោង AFSA និងសហគមន៍កសិកម្ម PUAC.